**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

សេចក្តីប្រកាសព័ត៌មានស្តីអំពីស្ថានភាពនយោបាយនៅកម្ពុជា

អូស្ត្រាលីមានការប្តេជ្ញាចិត្តខ្ពស់ចំពោះដំណើរលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងបានបង្ហាញជូនរាជរដ្ឋាភិបាលកម្ពុជា នូវការព្រួយបារម្ភជុំវិញការវិវត្តនយោបាយនាពេលថ្មីៗនេះ។

សកម្មភាពថ្មីបំផុតពាក់ព័ន្ធនឹងការស្នើសុំឱ្យមានការរំលាយនូវគណបក្សសង្គ្រោះជាតិបានបង្កឲ្យមានការព្រួយបារម្ភជាបន្តទៀត។ ការឈានទៅរកការលុបចោលគណបក្សប្រឆាំងធំចម្បងនឹងក្លាយជាជំហានថយក្រោយមួយនៅក្នុងដំណើរលទ្ធិប្រជាធិបតេយ្យ ព្រមទាំងជះឥទ្ធិពលដល់ការទទួលបានការបោះឆ្នោតជាតិដែលសេរី យុត្តិធម៌ និងមានតម្លាភាព នាខែកក្កដា ឆ្នាំ២០១៨ខាងមុខ។

ការប្តេជ្ញាចិត្តដ៏រឹងមាំរបស់ប្រជាពលរដ្ឋកម្ពុជាចំពោះលទ្ធិប្រជាធិបតេយ្យពហុបក្ស បានបង្ហាញយ៉ាងច្បាស់តាមរយៈចំនួនប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតនិងលទ្ធផលនៃការបោះឆ្នោតឃុំ-សង្កាត់ នាខែមិថុនា ឆ្នាំ២០១៧កន្លងទៅ។

អូស្ត្រាលីសូមលើកទឹកចិត្តដល់កម្ពុជាក្នុងការផ្តល់នូវបរិយាកាសអំណោយផលនិងប្រកបដោយសុវត្ថិភាពជូនប្រជាជនកម្ពុជា ដើម្បីអនុវត្តនូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំ។ វិស័យសារព័ត៌មានដែលរស់រវើក សង្គមស៊ីវិលដែលសកម្ម និងគណបក្សប្រឆាំងដែលអាចជឿជាក់បាន ជាសមាសធាតុនៃសង្គមប្រជាធិបតេយ្យ។

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧**